**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០០២ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២

# ប្រកាសរួម

# ស្តីពី

# ការផ្តល់រង្វាន់លើកទឹកចិត្តជូន

# ក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យ សាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងប្រកាសរួមលេខ ១០០១ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ ១ :**

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជូនក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ ២ :**

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា រវាងរដ្ឋបាលកណ្តាលនៃក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនឹងសាលាដំបូងរាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយផ្អែកលើភារកិច្ចក្នុងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយរដ្ឋបាលកណ្តាល និងការផ្តល់សេវាសាធារណៈដែលអនុវត្តដោយសាលាដំបូងរាជធានី ខេត្ត ។

**ប្រការ ៣ :**

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលនៃក្រសួងយុត្តិធម៌ និងសាលាដំបូងរាជធានី ខេត្ត កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួនពីការផ្តល់សេវាសាធារណៈ ដូចបានកំណត់ដោយប្រកាសរួមលេខ ១០០១ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងយុត្តិធម៌។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថា ថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទានជូនរដ្ឋបាលកណ្តាលនៃក្រសួងយុត្តិធម៌ និង សាលាដំបូងរាជធានី ខេត្ត សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូល ដែលបានកំណត់នៅក្នុងប្រការ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងយុត្តិធម៌ និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៤** :

ការផ្តល់ប្រាក់រង្វាន់ជូនក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបានបែងចែក ដូចខាងក្រោម ៖

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនក្រសួងយុត្តិធម៌ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ

ខ. ការបែងចែកសម្រាប់សាលាដំបូងរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនសាលាដំបូងរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ

**ប្រការ ៥** :

រដ្ឋបាលកណ្តាលនៃក្រសួងយុត្តិធម៌ និង សាលាដំបូងរាជធានី ខេត្ត ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលនៃក្រសួងយុត្តិធម៌ ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សាលាដំបូងរាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀត របស់រដ្ឋបាលកណ្តាល និង សាលាដំបូងរាជធានី ខេត្ត នៃក្រសួងយុត្តិធម៌ដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីថវិកាជាតិ (ប្រាក់ចំណូលដែលបានកាត់ទុកជាមុន)។

ការកត់ត្រាចំណូល និងចំណាយក្នុងកិច្ចប្រតិបត្តិការថវិកាជាតិ លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីទូទាត់ប្រាក់បុរេប្រទាន ដូចខាងក្រោម ៖

ក. ផ្នែកចំណូលៈ ត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ នូវចំនួនទឹកប្រាក់ចំណូលដែលបានបុរេប្រទាន ៖

- ចំពោះរដ្ឋបាលកណ្តាលនៃក្រសួងយុត្តិធម៌ ត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រចំណូលនោះ។
- ចំពោះសាលាដំបូងរាជធានី ខេត្ត ត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូល មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

ខ. ផ្នែកចំណាយៈ ត្រូវធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ ៦** :

ក្រោយពីបានបំពេញនីតិវិធី ដែលមានចែងក្នុងប្រការ ៥ ខាងលើ ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តត្រូវអនុវត្ត ដូចខាងក្រោម ៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងយុត្តិធម៌ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ ៧** :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨** :

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**អង្គ វង្សវឌ្ឍានៈ**

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត

**«ដើម្បីជូនជ្រាប»**

- ដូចប្រការ ៨ **«ដើម្បីអនុវត្ត»**
- ឯកសារ - កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធ

## ភ្ជាប់នឹងប្រកាសរួមលេខ ១០០២ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

## ស្តីពីការផ្តល់ទ្វាន់លើកទឹកចិត្ត ជូនក្រសួងយុត្តិធម៌(ក. យ) និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ក. សហវ)

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. យ | ក. សហវ |
| **I. សេវាសាធារណៈស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់របស់ក្រសួងយុត្តិធម៌** | | | | |
| 1 | ការចេញព្រឹត្តិបត្រថ្កោលទោសលេខ 3 | | | |
| 1.1 | ព្រឹត្តិបត្រថ្កោលទោស ( ជនជាតិខ្មែរ ក្រៅពីសិស្ស និងនិស្សិត ) | 30% | 69% | 1% |
| | | 30% | 69% | 1% |
| 1.2 | ព្រឹត្តិបត្រថ្កោលទោស( ជនជាតិខ្មែរជាសិស្ស ឬនិស្សិត ) | 30% | 69% | 1% |
| | | 30% | 69% | 1% |
| 1.3 | ព្រឹត្តិបត្រថ្កោលទោស ( ជនជាតិបរទេស ) | 30% | 69% | 1% |
| | | 30% | 69% | 1% |
| 1.4 | បកប្រែជាភាសាបរទេស( ព្រឹត្តិបត្រថ្កោលទោស ) | 10% | 89% | 1% |
| | | 10% | 89% | 1% |
| **II. សេវាសាធារណៈនៅតាមសាលាដំបូងក្ដី** | | | | |
| 1 | ពន្ធដាក់ពាក្យបណ្តឹង( គិតតាមតម្លៃកម្មវត្ថុនៃបណ្តឹង ដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ) | | | |
| 1.1 | ពន្ធដាក់ពាក្យបណ្តឹង មានតម្លៃត្រឹម 10លានរៀល | 50% | 49% | 1% |
| 1.2 | ពន្ធដាក់ពាក្យបណ្តឹង មានតម្លៃលើសពី 10លាន ដល់ 100លានរៀល | 50% | 49% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. យ | ក. សហវ |
| 1.3 | ពន្ធដាក់ពាក្យបណ្តឹង មានតម្លៃលើសពី 100លាន ដល់ 1000លានរៀល | 50% | 49% | 1% |
| 1.4 | ពន្ធដាក់ពាក្យបណ្តឹង មានតម្លៃលើសពី 1000លានរៀល | 50% | 49% | 1% |
| 2 | ពន្ធដាក់ពាក្យបណ្តឹងឧបាស្រ័យ | | | |
| 2.1 | ពន្ធដាក់ពាក្យបណ្តឹងឧទ្ធរណ៍ | 50% | 49% | 1% |
| 2.2 | ពន្ធដាក់ពាក្យបណ្តឹងសាទុក្ខទៅតុលាការកំពូល | 50% | 49% | 1% |
| 3 | ពន្ធដាក់ពាក្យបណ្តឹងជំនុំជម្រះសារជាថ្មី ( សាលាជម្រះក្តីគ្រប់ថ្នាក់ ) | 50% | 49% | 1% |
| 4 | ពន្ធដាក់ពាក្យសុំឱ្យចេញដីកាសម្រេចជាស់តឿន( សាលាជម្រះក្តីដំបូង ) | 50% | 49% | 1% |
| 5 | ពន្ធដាក់ពាក្យសុំទៅតុលាការឱ្យសម្រេចសេចក្តី ក្រៅពីពន្ធទាំងឡាយដែលបានរៀបរាប់ខាងលើ ( មាន 17 ប្រភេទ បានចែងក្នុងឧបសម្ព័ន្ធ 1 នៃប្រកាសលេខ 28 កយ ប្រក/07 របស់ក្រសួងយុត្តិធម៌ ) | 10% | 89% | 1% |
| 5.1 | ពាក្យប្តឹងជិតចិត្ត (មាត្រា 28) | 10% | 89% | 1% |
| 5.2 | ពាក្យសុំចូលរួមជួយអន្តរាគមន៍ ពាក្យសុំចូលរួមអន្តរាគមន៍ ក្នុងសហបណ្តឹង ( មាត្រា 43, 49 ) | 10% | 89% | 1% |
| 5.3 | ពាក្យសុំឲ្យថែរក្សាការពារភស្តុតាងដែលធ្វើមុនពេលដាក់ពាក្យបណ្តឹង ( មាត្រា 164, កឋាខណ្ឌទី2 ) | 10% | 89% | 1% |
| 5.4 | ពាក្យប្តឹងទាស់ ( មាត្រា 204 ) | 10% | 89% | 1% |
| 5.5 | ពាក្យប្តឹងជំទាស់ ( មាត្រា 301 ) | 10% | 89% | 1% |
| 5.6 | ពាក្យសុំតវ៉ាចំពោះការអនុវត្ត ( មាត្រា 344 ) | 10% | 89% | 1% |
| 5.7 | ពាក្យសុំឲ្យចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ ( មាត្រា 353 | 10% | 89% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. យ | ក. សហវ |
| 5.8 | ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ( មាត្រា 362 ) | 10% | 89% | 1% |
| 5.9 | ពាក្យសុំឲ្យផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ ( មាត្រា 366, 367, 369 ) | 10% | 89% | 1% |
| 5.1 | ពាក្យសុំឲ្យដីកាសម្រេចបង្គាប់ឲ្យប្រគល់( មាត្រា 390, 450, 459, 483 ) | 10% | 89% | 1% |
| 5.11 | ពាក្យសុំទាមទារឲ្យចែកចំណែក (មាត្រា 394, 409, 426 ) | 10% | 89% | 1% |
| 5.12 | ពាក្យសុំការចាត់ចែងការរក្សាការពារ ( មាត្រា 429 ) | 10% | 89% | 1% |
| 5.13 | ពាក្យសុំឲ្យលុបចោលនីតិវិធីលក់ដោយបង្ខំដោយដាក់ប្រាក់ធានា ( មាត្រា 461 ) | 10% | 89% | 1% |
| 5.14 | ពាក្យសុំការអនុញ្ញាតឲ្យនាវាធ្វើដំណើរ (មាត្រា 462 ) | 10% | 89% | 1% |
| 5.15 | ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ( មាត្រា 550 ) | 10% | 89% | 1% |
| 5.16 | ពាក្យសុំឲ្យផ្អាកការអនុវត្តរក្សាការពារ ( មាត្រា 551 ) | 10% | 89% | 1% |
| 5.17 | ពាក្យសុំឲ្យលុបចោលដីកាសម្រេចរក្សាការពារ ( មាត្រា 557, 558, 559) | 10% | 89% | 1% |
| 6 | ពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាព ក្រៅពីពន្ធដាក់ពាក្យសុំទៅតុលាការឲ្យសម្រេចសេចក្តីទាំង 17ខាងលើ ( មាន 4 ប្រភេទ បានចែងក្នុងឧបសម្ព័ន្ធ 2 ក្នុងប្រកាសលេខ 28 កយ.ប្រក/07 របស់ក្រសួងយុត្តិធម៌ ) | | | |
| 6.1 | ការទាមទារមើល ឬការទាមទារថតចម្លងសំណុំរឿង ។ ប៉ុន្តែក្នុងករណី ដែលភាគីទាមទារនៅពេលដែលរឿងក្តីកំពុងចាត់ការមិនតម្រូវឲ្យបង់ទេ ។ ចំពោះការចំណាយក្នុងការថតចម្លងឯកសារសំណុំរឿង ជាបន្ទុករបស់អ្នកទាមទារ ។ ( មាត្រា 258, 378, 538 ) | 10% | 89% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. យ | ក. សហវ |
| 6.2 | ការប្រគល់ឯកសារចម្លងយថាភូត ឬឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬឯកសារដកស្រង់នៃសំណុំរឿង ( មាត្រា 258, 378, 538 ) | 10% | 89% | 1% |
| 6.3 | ការប្រគល់នូវលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសេចក្តីសម្រេច ( មាត្រា 258, 378, 355 កថាខណ្ឌ 2 ជាអាទិ៍ ) | 10% | 89% | 1% |
| 6.4 | ពាក្យសុំឲ្យផ្តល់រូបមន្តអនុវត្ត ( មាត្រា 355 ជាអាទិ៍ ) | 10% | 89% | 1% |
| 7 | ប្រាក់ពិន័យផ្សេងៗ ដែលទទួលបានពីការសម្រេចរបស់តុលាការ | 75% | 24% | 1% |
| III. | **ប្រាក់ចំណូលផ្សេងៗនៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់** | | | |
| 1 | ប្រាក់លក់ឡាយឡុងពីវត្ថុចាប់យក រឹបអូសជាទ្រព្យសម្បត្តិរដ្ឋ | 80% | 19% | 1% |

**បញ្ជាក់:** ចំពោះចំណូលដែលប្រមូលបានពីការផ្តល់សេវាសាធារណៈដោយសាលាដំបូងរាជធានី ខេត្ត ការផ្តល់រង្វាន់លើកទឹកចិត្តជូនសាលាដំបូងរាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវអនុវត្តដូចអត្រាដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនេះ។